**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ០១ ស.ល.ន**

# លិខិតថ្លែងអំណរព្រះគុណ និងអរគុណ

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ទូលព្រះបង្គំជាខ្ញុំសូមបរមរាជានុញ្ញាតថ្លែងនូវអំណរព្រះមហាករុណាធិគុណជាអនេកកប្បការថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចម៉ែ ស្ថាប័នព្រឹទ្ធសភា រដ្ឋសភា ឯកឧត្តម អ្នកឧកញ៉ា លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំក្រសួងស្ថាប័ន មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ គ្រូពេទ្យ ក្រុមសង្គ្រោះ ក្រុមយុវជន ក្រុមស្ត្រីស្ម័គ្រចិត្ត ព្រមទាំងប្រជាជនទាំងអស់ ជាពិសេសប្រជាជននៅខេត្តកែបដែលបានចូលរួមយ៉ាងសកម្មក្នុងយុទ្ធនាការជួយសង្គ្រោះរុករកបងប្អូនកម្មកររងគ្រោះ ក្នុងឧបទ្ទវហេតុបាក់រលំអគារនៅភូមិកែប សង្កាត់កែប ខេត្តកែប កាលពីថ្ងៃសុក្រ ៩កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៣ ខែមករា ឆ្នាំ២០២០ កន្លងទៅ។

គុណូបការៈដ៏ប្រសើរថ្លៃថ្លាឧត្តុង្គឧត្តមរបស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង និងសម្ដេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ស្ថាប័នព្រឹទ្ធសភា រដ្ឋសភា ឯកឧត្តម អ្នកឧញ៉ា លោកឧញ៉ា លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួងស្ថាប័ន មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ គ្រូពេទ្យ ក្រុមសង្គ្រោះ ក្រុមយុវជន ក្រុមស្ត្រីស្ម័គ្រចិត្ត ព្រមទាំងប្រជាជនទាំងអស់បានបង្ហាញអំពីឆន្ទៈដ៏មោះមុតក្នុងការបូជាកម្លាំងកាយ កម្លាំងចិត្ត រួបរួមសាមគ្គីគ្នា ដើម្បីសម្រេចបាននូវការឈានទៅបញ្ចប់យុទ្ធនាការរុករកជនរងគ្រោះពីគំនរអគារបាក់រលំ ព្រមទាំងបានឧបត្ថម្ភជាថវិកា សម្ភារៈ គ្រឿងឧបភោគ បរិភោគ។ ជាលទ្ធផលយើងសម្រេចបាននូវការបញ្ចាប់យុទ្ធនាការរុករកត្រឹមថ្ងៃទីអាទិត្យ ១១កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៥ ខែមករា ឆ្នាំ២០២០ វេលាម៉ោង១១:៣៥នាទី ដោយរុករកបានជនរងគ្រោះទាំងអស់ពីគំនរអគារបាក់រលំ។

ជាថ្មីម្តងទៀតទូលព្រះបង្គំជាខ្ញុំ សូមទូលថ្វាយព្រះពរព្រះករុណាថ្លៃវិសេស ជាទីគោរពសក្ការៈ សូមព្រះអង្គទ្រង់ប្រកបដោយព្រះសុខភាពមាំមួន ព្រះកាយពលសិរីវឌ្ឍនា ព្រះបញ្ញាញាណភ្លឺថ្លា ឈ្លាសវៃ ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ចាកផុតពីព្រះរោគាព្យាធិនានា ដើម្បីព្រះអង្គទ្រង់គង់ប្រថាប់ជាម្លប់យ៉ាងត្រជាក់ត្រជុំ សុខដុមរមនា របស់មាតុភូមិកម្ពុជា ជារៀងរហូតទៅ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម អ្នកឧញ៉ា លោកឧញ៉ា លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំក្រសួងស្ថាប័ន មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ គ្រូពេទ្យ ក្រុមយុវជន ក្រុមស្ត្រីស្ម័គ្រចិត្ត ព្រមទាំងប្រជាជនទាំងអស់ សូមសមប្រកបតែនឹងពុទ្ធពរទាំង៥ប្រការ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃអាទិត្យ ១១ កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែមករា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**